រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

062KH01A-01

ពួកឆ្កែចចក



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៦២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រទានប្រាជ្ញា ដើម្បីអាចមើលស្គាល់ពួកឆ្កែចចក ដែលមារសាតាំងចាត់អោយមកវាយប្រហារហ្វូងចៀមរបស់អ្នក ។

ពួកអារក្សខិតខំបញ្ចូលគោលជំនឿក្លែងក្លាយ មកក្នុងក្រុមជំនុំរបស់យើង (ម៉ាថាយ ៧:១៥, ១ ធីម៉ូថេ ៤:១) ។ ពួកអារក្សដឹកនាំពួកអ្នកជឿខ្លះអោយធ្វើខុស ហើយធ្វើអោយពួកគេក្លាយជា «ឆ្កែចចក» ។ ឆ្កែចចកជាអ្នកដែលខិតខំប្រកាសពីគោលជំនឿក្លែងក្លាយ ឬ ឆក់យកសមាជិកក្រុមជំនុំ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន និងបណ្តាលអោយមានការបែកបាក់គ្នា (កិច្ចការ ២០:២៨-៣០) ។



កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ចចកបំបែកបំបាក់

ឆ្កែចចកបំបែកបំបាក់ ជាឆ្កែចចកដែលបណ្តាលអោយមានគ្រោះថ្នាក់ណាស់ ។ ពួកបំបែកបំបាក់ មិនគោរពតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ (ម៉ាថាយ ២៤:១១, ២៤) ឬ តាមពួកអ្នកដឹកនាំក្រុមជំនុំទេ ហើយពួកវាបំផ្លាញឯកភាពក្នុងព្រះអម្ចាស់ ។



ពួកបំបែកបំបាក់មិនផ្សាយដំណឹងល្អទេ តែពួកគេទាក់ទាញសមាជិក ដែលទន់ខ្សោយអោយបែកចេញពីហ្វូង (ក្រុមជំនុំ) (រ៉ូម ១៥:២០-២១, ២ កូរិនថូស ១០:១៥-១៨, កាឡាទី ១:៦-៨) ។

© Project WorldReach © SEAN



ចចកនេះក្លែងខ្លួនពាក់ស្បែកចៀម (ម៉ាថាយ ៧:១៥)។ វាបំភាន់ក្មេកសមាជិកឯទៀត ដោយធ្វើដូចជាផ្សព្វផ្សាយដំណឹងល្អ ប៉ុន្តែវាបណ្តាលអោយមានការបែកបាក់គ្នាទេវិញ ។



- បើសិនជាមានអ្នកណាម្នាក់យកគោលជំនឿថ្មី ដែលផ្ទុយពីគោលជំនឿ ដែលអ្នកបានរៀនពីព្រះគម្ពីរ មកប្រកាស សូមធ្វើអោយគេដឹងថា អ្នកមិនយល់ស្របជាមួយគេទេ ។ បើសិនជាអ្នកនោះនៅតែប្រព្រឹត្តខ្លួនជាចចកទៀត ត្រូវចៀសចេញឱ្យឆ្ងាយពីអ្នកទាំងនោះទៅ (រ៉ូម ១៦:១៧) ។ យើងត្រូវព្រមានអ្នកដែលបណ្តាលអោយមានការបែកបាក់ ។ បើពួកគេមិនព្រមកែប្រែ យើងត្រូវបណ្តេញគេអោយចេញពីក្រុមជំនុំយើង (ទីតុស ៣:១០-១១) ។ បើសិនជាក្រុមជំនុំមិនអាចដោះស្រាយបញ្ហា ដែលទាក់ទងនឹងឆ្កែចចកបានទេ ក្រុមជំនុំត្រូវសូមអោយពួកអ្នកដឹកនាំរបស់ក្រុមជំនុំផ្សេងទៀត មកស៊ើបអង្កេត និង ជួយ (កិច្ចការ ជំពូក ១៥) ។

កិច្ចការដែលត្រូវអនុវត្ត

- បង្រៀនហ្វូងចៀមរបស់អ្នកអំពី កិច្ចការ ២០:២៨-៣១ ដោយដាស់តឿនប្រាប់ពួកគេពីសត្វចចកគ្រប់ប្រភេទ ។ បើសិនជាខ្លួនអ្នកជាចចក សូមកែប្រែចិត្តគំនិតពេលនេះ ហើយទៅសូមទោសពួកអ្នកដែលអ្នកបានធ្វើខុសទៅលើ និង សងប្រាក់ ឬ របស់ទ្រព្យដែលអ្នករកបាន ដោយមធ្យោបាយមិនល្អ ទៅម្ចាស់ដើមវិញ ។

- បង្រៀនអ្នកជឿអោយចេះស្រឡាញ់គ្នាទៅវិញទៅមក ។ បើសិនជាមានអ្នកជឿខ្លះមិនត្រូវគ្នា ត្រូវជួយពួកគេអោយត្រូវរ៉ូវជាគ្នាវិញ ។ អ្នកដែលមានគំនុំខឹងនឹងអ្នកណាម្នាក់ក្នុងចិត្ត ត្រូវអធិស្ឋាន យកល្អគួរតមអាហារផងដែរ រហូតដល់ព្រះ-វិញ្ញាណដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ជំរះសំអាតគំនុំចេញអស់ពីចិត្តគាត់ (ម៉ាថាយ ៥:២៣-២៤) ។

- ធ្វើអោយអ្នកជឿ ដែលបានកែប្រែចិត្តគំនិតម្នាក់ៗ ជឿជាក់ថា ព្រះជាម្ចាស់បានអត់ទោសអោយគេពេញលេញ និង ជារៀងរហូត ក្នុងព្រះយេស៊ូគ្រីស្ត និង ដោយសារកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់គេ (កូឡូស ២:៩-១០, ១ យ៉ូហាន ១:៧, ៥:១៣) ។

«ជនប្រភេទនោះ សុទ្ធតែជាគ្រីស្តទូតក្លែងក្លាយ អ្នកបន្លំធ្វើការអ្នកក្លែងខ្លួនធ្វើជាគ្រីស្តទូតរបស់ព្រះគ្រីស្ត ។ ត្រង់នេះ សូមកុំឆ្ងល់អ្វីឡើយ សូម្បីតែមារសាតាំងផ្ទាល់ ក៏បានក្លែងខ្លួនធ្វើជាទេវតានៃពន្លឺដែរ ។ ដូច្នេះ បើពួកអ្នកបំរើរបស់វា ក្លែងខ្លួនធ្វើជួចជាអ្នកបំរើសេចក្តីសុចរិតនោះ គ្មានអ្វីចំឡែកសោះឡើយ ។ អ្នកទាំងនោះនឹងវិនាសស្របតាមអំពើ ដែលខ្លួនបានប្រព្រឹត្តជាមិនខាន» ។

(២ កូរិនថូស ១១:១៣-១៥)



អ្នកបំបែកបំបាក់ បង្រៀនព្រះគម្ពីរគ្រាន់តែដើម្បី :

☐ កសាងយើង ។

☐ បំភាន់ភ្នែកយើងតែប៉ុណ្ណោះ ។



ចចកបំបែកបំបាក់ធ្វើសកម្មភាព នៅពេលដែលគ្រូគង្វាលមិនបានប្រុងប្រយ័ត្ន ។ វាប្រើពាក្យសំដីនិយាយដូចចៀម ដូចជាអ្នកជឿដែលស្រឡាញ់បងប្អូនរួមជំនឿដែរ ។ សូមកុំភ្លេចថា មារសាតាំងផ្ទាល់បានប្រើព្រះបន្ទូលព្រះជាម្ចាស់ ដើម្បីសាកល្បងបោកបញ្ឆោតព្រះអម្ចាស់យេស៊ូគ្រីស្ត (ម៉ាថាយ ៤:៥-៦) ។



៧- ចចកផារីស៊ីបំបែកបំបាក់ពួកអ្នកជឿ ដោយសារ :

☐ សេចក្តីស្រឡាញ់ ។

☐ ក្រិត្យវិន័យរបស់គេ ។

៨- ចចកជាច្រើនធ្វើអោយក្រុមជំនុំចុះខ្សោយ ដោយសារការលោភលន់របស់ពួកគេ គឺដូចជាចចកផារីស៊ីធ្វើអោយក្រុមជំនុំចុះខ្សោយ ដោយសារក្រិត្យវិន័យរបស់ពួកគេដែរ ។
ចចកលោភលន់ច្រើនតែធ្វើការងារ :

☐ ដោយសេចក្តីស្រឡាញ់ ។

☐ ដើម្បីអោយមានទ្រព្យសម្បត្តិច្រើន ។

៤- ចចកក៏ដូចមារសាតាំងដែរ គឺប្រើព្រះគម្ពីរ :

- ☐ ដើម្បីអោយយើងទុកចិត្ត ហើយពួកគេអាចធ្វើអ្វីតាមផ្លូវរបស់ពួកគេ ។
- ☐ កសាងក្រុមជំនុំមួយ ដែលមានឯកភាព ។

៥- ចចកចង់ធ្វើអ្វីតាមចិត្តគេ ។ គេមានភាពខាងក្រៅដូចជាអ្នកដែលស្រឡាញ់ព្រះជាម្ចាស់ណាស់ ។ គេក្លែងខ្លួនធ្វើជាចៀម ។ គេនិយាយដូចទេវតានៃពន្លឺ ដើម្បីបំភាន់ភ្នែកពួកអ្នកដែលទុកចិត្តលើព្រះយេស៊ូ ។ នៅពេលដែលចចកមួយខិតខំបំបែកបំបាក់ក្រុមជំនុំ យើងត្រូវ :

- ☐ ចៀសចេញអោយឆ្ងាយពីអ្នកនោះ ។
- ☐ ទិតៀនអ្នកនោះ ។

៦- យើងមិនត្រូវយកចិត្តទុកដាក់ចំពោះពាក្យសំដីរបស់ចចកទេ ហើយមិនត្រូវចាប់អារម្មណ៍លើចចកដែរ ។ ពេលខ្លះ ចចកនិយាយការពិត តែធ្វើសកម្មភាព :

- ☐ ដើម្បីបង្រួបបង្រួម ។
- ☐ ដើម្បីបំបែកបំបាក់ ។

ចោរមិនដែលចូលក្នុងក្រោលចៀមតាមផ្លូវត្រឹមត្រូវ គឺតាមទ្វារដែលជាព្រះយេស៊ូទេ (យ៉ូហាន ១0:៧-៩) ។ ហេតុនេះវាមិនមែនមកដោយសារព្រះអម្ចាស់អនុញ្ញាតិនោះទេ ។ ទោះបីជាវានិយាយអំពីព្រះគម្ពីរក៏ដោយ តែវាគ្រាន់តែចង់ :

- ☐ លួចចៀមប៉ុណ្ណោះ ។
- ☐ ជួយចៀម ។

«ខ្ញុំដឹងច្បាស់ថា ពេលខ្ញុំចេញផុតទៅ នឹងមានមនុស្សចិត្តសាហាវដូចចចក នាំគ្នាចូលមកក្នុងចំណោមបងប្អូន គេនឹងធ្វើបាបក្រុមអ្នកជឿឥតត្រាប្រណីឡើយ ថែមទាំងមានអ្នកខ្លះក្នុងចំណោមបងប្អូននាំគ្នាពោលពាក្យបញ្ឆោត ដើម្បីទាក់ទាញពួកសាវ័កអោយទៅតាមគេទៀតផង ។ ហេតុនេះ សូមបងប្អូនប្រុងស្មារតីអោយមែនទែន ដោយនឹកចាំថា ខ្ញុំបានដាស់តឿនបងប្អូនគ្រប់ៗរូបទាំងទឹកភ្នែក ក្នុងរវាងបីឆ្នាំ ទាំងយប់ ទាំងថ្ងៃ ឥតមានឈប់ឡើយ » ។

(កិច្ចការ ២0:២៩-៣១)



ការប្រឡង (សំនួរសង្ខេបមេរៀន)

«ប្រសិនបើមាននរណាម្នាក់មករកអ្នករាល់គ្នា តែមិននាំព្រះឱវាទនេះមកទេ កុំទទួលគេនៅក្នុងផ្ទះអ្នករាល់គ្នាឡើយ ហើយក៏មិនត្រូវជំរាបសួរគេផង » ។

(២ យ៉ូហាន ខ ៩-១០)

១- ចចកក្បាលធំ :

- ☐ ចេះបន្ទាបខ្លួន ។
- ☐ គិតថា ខ្លួនចេះដឹងគ្រប់យ៉ាង ។

២- ចចកបំបែកបំបាក់អ្នតខ្លួនណាស់ ។ គេចូលចិត្ត :

- ☐ ទិតៀនពួកអ្នកចាស់ទុំ និង គ្រូគង្វាល ។
- ☐ លើកទឹកចិត្តពួកអ្នកជឿឱ្យស្រុះស្រួលជានានឹងគ្នា ។

៣- ចចកលួចចៀមជាច្រើន ចូលចិត្តទិតៀនណាស់ ។ ពួកគេចូលទៅក្នុងហ្វូងចៀម :

- ☐ ដោយសារក្រុមជំនុំអនុញ្ញាតិ ។
- ☐ ដោយគ្មានការអនុញ្ញាតិ ។



គ្រួគង្វាលដែលវែឆ្ងាតចេះស្គាល់ និង ការពារសមាជិករបស់ក្រុម-ជំនុំខ្លួន បើមិនដូច្នោះទេ ពួកសត្វចចកនឹងកំទេចហ្វូងចៀមបានមិនខាន ។

« បងប្អូនអើយ ខ្ញុំសូមដាស់តឿនបងប្អូនអោយប្រុងប្រយ័ត្ននឹងពួកអ្នកដែលបង្កអោយមានការបាក់បែកគ្នា និង នាំអោយបងប្អូនរវាតចិត្តចេញពីជំនឿ ដោយគេប្រព្រឹត្តផ្ទុយពីសេចក្តីបង្រៀនដែលបងប្អូនបានទទួល ។ សូមបងប្អូនចៀសចេញអោយឆ្ងាយពីអ្នកទាំងនោះទៅ » ។

(រ៉ូម ១៦:១៧)

លោកប៉ូលនិយាយថា÷

« ខ្ញុំមិនដែលចង់បានមាសប្រាក់ ឬសម្លៀកបំពាក់អ្វីពីនរណាឡើយ ។ បងប្អូនជ្រាបស្រាប់ហើយថា ខ្ញុំបានធ្វើការដោយផ្ទាល់ដៃ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់ខ្ញុំ និង សេចក្តីត្រូវការរបស់អស់អ្នកដែលនៅជាមួយខ្ញុំ ។ ក្នុងគ្រប់កិច្ចការទាំងអស់ ខ្ញុំតែងតែប្រាប់អោយបងប្អូនដឹងថា ត្រូវតែធ្វើការនឿយហត់បែបនេះឯង ដើម្បីជួយទំនុកបំរុងអស់អ្នកដែលក្រខ្សត់ ហើយត្រូវចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់យេស៊ូថា÷ "បើអោយនោះ នឹងបានសុភមង្គលច្រើនជាងទទួល" » ។

(កិច្ចការ ២០:៣៣-៣៥)

តើអ្នកចេះស្កប់ចិត្តនឹងអ្វីដែលអ្នកមានដែរឬទេ ? ។

ចចកផារីស៊ី

មានចចកមួយទៀត ដែលយើងអាចហៅថា «ផារីស៊ី» ព្រោះវាដើរហិតក្លិន បានន័យថា ពួកផារីស៊ីប្រមាទមើលងាយ និង ចង់ដឹងរឿងអ្នកដទៃ ដើម្បីរកចំណុចខ្សោយសំរាប់ទិតៀន ។

ពួកចចកផារីស៊ីបង្កើតវិន័យយ៉ាងតឹងរ៉ឹងរបស់ខ្លួនផ្ទាល់ ដើម្បីបង្ខំអោយមនុស្សអនុវត្តតាម ដែលបណ្តាលឱ្យមនុស្សនឿយហត់ និងមានបន្ទុកធ្ងន់ ។ ពួកផារីស៊ីធ្វើអោយពួកអ្នកជឿ ដែលទន់ខ្សោយសង្ស័យមិនជឿជាក់ថា ខ្លួនបានព្រះគ្រីស្តលើកលែងទោសទេ ដើម្បីនាំពួកអ្នកជឿទាំងនោះ អោយធ្វើតាមបំណងរបស់ពួកគេវិញ ។



ហេតុអ្វីបានជាព្រះជាម្ចាស់ចាត់ទុកការលោភលន់ជាបញ្ហាធ្ងន់ធ្ងរ ?

សូមសរសេរពីយោបល់របស់អ្នក :

© Project WorldReach © SEAN

លោកប៉ូលសរសេរថា÷

«ខ្ញុំនិយាយដូច្នេះ មិនមែនមកពីខ្ញុំខ្វះខាតទេ ដ្បិតខ្ញុំបានរៀនអោយចេះស្កប់ចិត្ត ក្នុងគ្រប់កាលៈទេសៈ ។ ទោះបីទ័លក្រក្តី មានបរិបូណ៌ក្តី ខ្ញុំក៏ចេះរស់ដែរ ។ ខ្ញុំបានអប់រំចិត្តក្នុងគ្រប់កាលៈទេសៈនិង គ្រប់ទីកន្លែង គឺថាទោះបីបរិភោគឆ្អែតក្តី អត់ឃ្លានក្តី មានបរិបូណ៌ក្តី ឬ ខ្វះខាតក្តី ខ្ញុំស្កប់ចិត្តជានិច្ច ។ ខ្ញុំអាចទ្រាំបានទាំងអស់ ដោយរួមជាមួយព្រះអង្គដែលប្រទានកម្លាំងអោយខ្ញុំ » ។

(ភីលីព ៤:១១-១៣)

អ្នកចាស់ទុំពិត មិនត្រូវ «រកប្រាក់តាមរបៀបថោកទាប » នោះឡើយ (ទីតុស ១:៥-៧) ។ គាត់ «មិនស្រឡាញ់ប្រាក់ឡើយ » (១ ធីម៉ូថេ ៣:៣) ។ អ្នកជំនួយពិត មិនត្រូវ «រកប្រាក់តាមរបៀបថោកទាប »នោះឡើយ (១ ធីម៉ូថេ ៣:៨) ។ អត្ថបទព្រះគម្ពីរជាងមួយរយអត្ថបទ ដាស់តឿនប្រាប់យើងអំពីគ្រោះថ្នាក់ដែលបណ្តាលមកពីការលោភលន់ ! ។

ជួនកាល ចចកនេះដាក់បញ្ញត្តិតម្រូវឱ្យពួកអ្នកជឿប្រតិបត្តិតាមប្រពៃណីខ្លះរបស់មនុស្ស ឬ ក្រិត្យវិន័យអំពីពិធីសាសនា នៅក្នុងសម្ពន្ធមេត្រីចាស់ ។ បើយើងប្រកាន់តាមបទបញ្ញត្តិទាំងនេះខ្លាំងពេក យើងនឹងក្លាយជា «អ្នកគោរពតែក្រិត្យវិន័យ » ។ បើសិនជាអ្នកណាម្នាក់ខិតខំប្រកាន់តាមក្រិត្យវិន័យចាស់ ដើម្បីអោយបានសង្គ្រោះ អ្នកនោះចាំបាច់ត្រូវធ្វើតាមក្រិត្យវិន័យទាំងមូល (យ៉ាកុប ២:១០) ។ ប៉ុន្តែ ដោយសារ គ្មានអ្នកណាអាចធ្វើតាមក្រិត្យវិន័យបានទាំងអស់ទេនោះ ទើបអស់អ្នកដែលពឹងផ្អែកលើការប្រតិបត្តិតាមក្រិត្យវិន័យ ត្រូវបណ្តាសាវិញ (កាឡាទី ៣:១០) ។ យើងស្ថិតនៅក្រោមក្រិត្យវិន័យរបស់សម្ពន្ធមេត្រីថ្មីនៃសេចក្តីស្រឡាញ់ (ម៉ាថាយ ២២:៣៤-៤០) ។

ចចកបង្កើតក្រិត្យវិន័យ បង្កើត និង បង្ខំអោយមនុស្សប្រតិបត្តិតាមក្រិត្យវិន័យ ដើម្បីបង្ខំមនុស្សអោយដើរតាមផ្លូវរបស់ខ្លួន ដោយមិនគិតពីសេរីភាព ដែលយើងត្រូវមានក្នុងព្រះគ្រីស្តទេ ។

ជួនកាល យើងបង្កើតបទបញ្ញត្តិថ្មី ដែលមិនមាននៅក្នុងព្រះគម្ពីរ ទេ ។ ប៉ុន្តែ ទោះជាយើងបង្កើតបទបញ្ញត្តិទាំងនោះក្នុងគោលដៅ ល្អក៏ដោយ បើសិនជាបទបញ្ញត្តិទាំងនោះ បង្អាក់ដំណើរការ និង ការរីកចំរើនរបស់ក្រុមជំនុំមូលដ្ឋាន យើងត្រូវបោះបង់ចោលបទ បញ្ញត្តិទាំងនោះ ។ អស់អ្នកដែលរស់នៅតាមព្រះវិញ្ញាណ ប្រតិបត្តិ តាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអម្ចាស់ ពីព្រោះអ្នកនោះ ស្រឡាញ់ព្រះជាម្ចាស់ និង ស្រឡាញ់អ្នកជិតខាងរបស់ខ្លួន : *«អ្នក មានចិត្តស្រឡាញ់ មិនដែលប្រព្រឹត្តអាក្រក់ដល់បងប្អូនឯទៀតៗ ឡើយ ។ ដូច្នេះ សេចក្តីស្រឡាញ់ នាំអោយប្រតិបត្តិតាមវិន័យ បានពេញលក្ខណៈ »* ។

(រ៉ូម ១៣:១០)

អ្វីៗដែលពួកសត្វចចកចាត់ទុកជាសំខាន់ ដូចជាក្រិត្យវិន័យអំពីការ បរិភោគថ្ងៃសំខាន់ ។ល។ មិនសូវសំខាន់ដូចដែលពួកគេគិតនោះ ទេ (រ៉ូម ១៤:១-៦) ។ *«ដ្បិតព្រះរាជ្យរបស់ព្រះជាម្ចាស់មិន មែនអាស្រ័យនៅលើការស៊ីផឹកនោះទេ គឺអាស្រ័យនៅលើសេចក្តី សុចរិត សេចក្តីសុខសាន្ត និង អំណរដែលមកពីព្រះវិញ្ញាណដ៏ វិសុទ្ធ »* ។

(រ៉ូម ១៤:១៧)

ក្រុមជំនុំនឹងមិនមានទឹកចិត្តទទួលខុសត្រូវធ្វើអំណោយ ឬ ដាក់ ដង្វាយដប់ភាគរយទេ បើសិនជាពួកគេមិនដឹងថា អ្នកដឹកនាំចាត់ ចែងប្រើប្រាស់ដង្វាយដោយរបៀបណានោះ ។

ក្រុមជំនុំ ឬ ពួកអ្នកដឹកនាំក្រុមជំនុំ ត្រូវផ្តល់អំណាចឱ្យហេរញ្ញិក ប្រើប្រាស់ដង្វាយ តាមបញ្ជីចំណាយ ដែលបានកំណត់ក្នុងគំរោង ថវិកា ។

ហេរញ្ញិកត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រុមជំនុំ ឬគណៈកម្ម-ធិការ ។ បើសិនជាក្រុមជំនុំឧបត្ថម្ភគ្រួគង្វាលរបស់ខ្លួនតាមសេចក្តី បង្គាប់របស់ព្រះគម្ពីរ ក្នុង ១ ធីម៉ូថេ ៥:១៧-១៨ នោះត្រឹមត្រូវ និង ល្អបំផុត ។

ចចកកំណាញ់ខ្លះឆ្លៀតយកផលប្រយោជន៍ពីពួកអ្នកជឿ និង ពី ការជឿទុកចិត្តរបស់បងប្អូនក្នុងព្រះគ្រីស្ត ដោយសុំខ្ចីលុយ ។ រួច ពួកគេមិនសងវិញទេ ។ នៅពេលដែលចចកទាំងនោះ លែងអាច ឆ្លៀតឱកាសកេងប្រវ័ញ្ចពួកអ្នកជឿក្នុងក្រុមជំនុំមួយហើយ ពួកគេ ទៅរកក្រុមជំនុំមួយទៀត ។ ២ ថេស្សាឡូនិក ៣:១០ បង្គាប់ថា÷ *«អ្នកណាមិនព្រមធ្វើការ អ្នកនោះក៏មិនត្រូវបរិភោគដែរ »* និង *«សូមបងប្អូនឈប់និយាយកុហកទៅ »* (អេភេសូ ៤:២៥) ។ ទឹកចិត្តកំណាញ់នាំអោយភូតភរ និង លួចបន្តំ ។

ចចកក្បាលធំ (អ្នតបំបៅង)

ចចកនេះទុកចិត្តលើប្រាជ្ញាដ៏ឈ្លាសវៃរបស់ខ្លួនឯងពេក គឺ *«ប្រសិនបើមានអ្នកណាម្នាក់នឹកស្មានថាខ្លួនចេះដឹងហើយ បានសេចក្តីថា អ្នកនោះនៅមិនទាន់ចេះដឹង ដូចដែលខ្លួនត្រូវចេះដឹងនោះឡើយ »* ។

(១ កូរិនថូស ៨:២)



គ្មានអ្នកណាអាចស្គាល់ព្រះជាម្ចាស់ ដោយសារប្រាជ្ញារបស់មនុស្សលោកឡើយ (១ កូរិនថូស ១:២១-២៣) ។ «មនុស្សមានប្រាជ្ញា»ខ្លះ បដិសេធការអស្ចារ្យរបស់ព្រះជាម្ចាស់ ។ «មនុស្សមានប្រាជ្ញា»ខ្លះទៀត បង្កើតគោលលទ្ធិ និង ការប្រតិបត្តិរបស់ខ្លួនបន្ថែមទៀត ។

បើសិនជាគ្រូគង្វាលខិតខំរកប្រាក់កាសពីគ្រប់កន្លែង ដែលគាត់អាចរកបាន គឺពីក្រុមជំនុំឯទៀត ឬ ប្រទេសដទៃ ក្រុមជំនុំរបស់គាត់នឹងមិនសូវចេះបំពេញភារៈកិច្ចរបស់ខ្លួន ដែលត្រូវដាក់ដង្វាយដប់ភាគរយ និង ឧបត្ថម្ភគ្រូគង្វាលរបស់ខ្លួនទេ ។ ហេតុដូច្នេះ ក្រុមជំនុំមិនរីកចំរើនទៅមុខខាងព្រលឹងវិញ្ញាណទេ ។

ចចកលោភលន់ខ្លះ បានទទួលដង្វាយយ៉ាងច្រើន ពេលពួកគេរៀបចំធ្វើសកម្មភាពអ្វីមួយ ។ ពួកគេពន្លើសបន្ថែមសេចក្តីត្រូវការ ហើយជំរុញអោយដាក់ដង្វាយច្រើនហួសពីចាំបាច់ ។ បើសិនជាព្រះជាម្ចាស់ត្រាស់ហៅអោយរៀបចំធ្វើសកម្មភាពអ្វីមួយ នោះមិនចាំបាច់ពន្លើសបន្ថែមសេចក្តីត្រូវការ ភ្ងូតភរ ឬ បង្ខំ ដើម្បីឱ្យបានប្រាក់កាសទេ គឺព្រះជាម្ចាស់នឹងឧបត្ថម្ភចំពោះគ្រប់សេចក្តីត្រូវការតាមរយៈការអធិស្ឋាន និង ជំនឿ ។

ចចកខ្លះទៀត មិនអនុញ្ញាតិអោយក្រុមជំនុំរៀបចំគំរោងថវិកាទេ ។ ចចកលោភលន់ខ្លះទៀត ប្រមូលយកដង្វាយទាំងអស់របស់ក្រុម-ជំនុំរបស់ខ្លួនមកប្រើប្រាស់ខ្លួនឯង ។ ពួកគេមិនដែលធ្វើរបាយ-ការណ៍ពីការប្រើប្រាស់ប្រាក់ដង្វាយទេ ។ ត្រូវចាត់ចែងប្រើប្រាស់ប្រាក់ដង្វាយ ដោយចំហ ច្បាស់លាស់ ទៀងត្រង់ និង ស្មោះត្រង់ ដើម្បីថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់ ។

ចចកល្ងូ

ចចកមួយទៀត ឡូឡាក្តុងក្តាំងណាស់ ។ យើងអាចមើលស្គាល់ចចកនោះ ដោយសារចចកនោះមានមាត់ធំ ដែលបើកជានិច្ច ដើម្បីនិយាយជជែកពីខ្លួនឯង ។ គាត់មានជំនឿដែលពឹងផ្អែកលើបទពិសោធន៍របស់គាត់ផ្ទាល់ ។ គាត់ចង់បានតែបទពិសោធន៍ដែលធ្វើអោយគាត់រំជួលចិត្តតែប៉ុណ្ណោះ ។ ពេលគាត់អធិស្ឋានគាត់អធិស្ឋានស្រែកខ្លាំងៗ ដើម្បីឱ្យគេចាប់អារម្មណ៍លើគាត់ ។ គាត់ធ្វើអោយមានការច្របូកច្របល់ក្នុងពេលថ្វាយបង្គំ ហើយមិនចេះទប់ចិត្តទេ ។

«ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ស្ថិតនៅក្រោមអំណាចរបស់អ្នកថ្លែងព្រះបន្ទូល ដ្បិតព្រះជាម្ចាស់មិនសព្វព្រះហឫទ័យនឹងការខ្វះសណ្តាប់ធ្នាប់ទេ គឺព្រះអង្គសព្វព្រះហឫទ័យនឹងសេចក្តីសុខសាន្ត ។ ...ត្រូវធ្វើការទាំងអស់នេះ ដោយសមរម្យ និង ដោយមានសណ្តាប់ធ្នាប់ » ។

(១ កូរិនថូស ១៤:៣២-៣៣, ៤០)

អ្នកជឿក្លាយជាអ្នកដែលស្រឡាញ់ប្រាក់ ! គួរអោយសោកស្តាយណាស់ ដែលអ្នកជឿទៅជាធ្លាក់ខ្លួនស្រឡាញ់ប្រាក់នោះ ! ។ ការប្រើក្រុមជំនុំ ដែលជាព្រះកាយដ៏វិសុទ្ធរបស់ព្រះយេស៊ូ និង ជាក្លួនក្រមុំរៀបការរបស់ព្រះមហាក្សត្ររបស់យើង ដើម្បីរកលុយ ជារបៀបធ្វើកិច្ចការបំរើ ដែលគួរអោយស្អប់ខ្ពើមបំផុត ! ។

គ្រីស្តជនអ្នកបំរើកំណាញ់ខ្លះ ទាមទារប្រាក់ឧបត្ថម្ភខ្ពស់ពីអង្គការ ឬក្រុមជំនុំរបស់ពួកគេ ប្រៀបដូចជាពួកគេជាអ្នកជំនួញ ! ។

យោងទៅតាម ហេប្រឺ ១៣:៥ តើយើងត្រូវរស់នៅរបៀបណា ?

☐ ដោយមានចិត្តលោភលន់ និង ចេះប្រើកលល្បិច ។

☐ ដោយជំនឿ ។

ពួកចចកលោភលន់ទាំងនេះ មិនរវល់គិតគូរអំពីការផ្សព្វផ្សាយដំណឹងល្អ នៅក្នុងកន្លែងថ្មីៗទេ ។ ពួកគេរក្សាទុកប្រាក់កាសទាំងអស់សំរាប់ក្រុមជំនុំរបស់ពួកគេ ព្រោះពួកគេចង់មានអំណាចលើប្រាក់កាសទាំងនោះ ។

មនុស្សខ្លះចង់ធ្វើជាគ្រូគង្វាល ដើម្បីអាចទទួលបានរបស់របរ អាច
មានឱកាសធ្វើដំណើរទៅបរទេស មានប្រាក់ខែ មានការងារធ្វើ
។ល។ ដោយសារពួកគ្រីស្តទូត និង អង្គការនានា ។ ក្នុងករណី
នេះ មូលហេតុទីមួយ ដែលនាំអោយគេធ្វើជាគ្រូគង្វាល ឬ ទៅ
រៀននៅសាលាព្រះគម្ពីរ គឺដើម្បីប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ ។
គ្រូគង្វាលខ្លះបានទាំងយកប្រាក់ទៅទិញអំណោយទានសំរាប់មនុស្ស
ដើម្បីធ្វើអោយគេសុខចិត្តទៅចូលរួមក្នុងក្រុមជំនុំរបស់ខ្លួន ។ អំពើ
ទាំងនេះ សុទ្ធតែបណ្តាលមកពីចិត្តលោភលន់ ។ អាកប្បកិរិយា
ស្វែងរកប្រយោជន៍ផ្ទាល់ខ្លួនរបៀបនេះ ព្រះជាម្ចាស់មិនប្រទានពរ
ទេ ។

នេះមានន័យថា ចចកលោភលន់ក៏បានជ្រៀតចូលក្នុងក្រុមជំនុំ
ដំណឹងល្អដែរ ។ ពួកចចកទាំងនោះ តែងតែចង់ប្រើសាសនា
ដើម្បីប្រមូលទ្រព្យសម្បត្តិ ។ មារសាតាំងល្បួងគ្រូគង្វាលខ្លះអោយ
មានចិត្តកំណាញ់ :

*«អ្នកត្រូវដឹងអោយច្បាស់ថា នៅពេលចុងក្រោយបង្អស់ នឹងមាន
គ្រាលំបាក មនុស្សម្នានឹងមានចិត្តអាត្មានិយម ស្រឡាញ់ប្រាក់
ក្រអឺតក្រទម អួតខ្លួន ប្រមាថ...»* ។

(២ ធីម៉ូថេ ៣:១-២)



© Project WorldReach © SEAN

ចចកដែលតម្កើងខ្លួន

ចចកដែលធ្វើកិច្ចការផ្សេងៗ ដើម្បីអោយមនុស្សម្នាកោតសរសើរ មិនលើកសិរីរុងរឿងរបស់ព្រះអម្ចាស់យេស៊ូគ្រីស្តទេ តែលើកតម្កើងខ្លួនឯងវិញ ។ គាត់អួតថា ខ្លួនអាចទាក់ទងផ្ទាល់ជាមួយព្រះ-ជាម្ចាស់ ។ គាត់ទាមទារអោយធ្វើអ្វីៗ ដែលចំឡែក ។ គាត់តមអាហារ និង អធិស្ឋានស្រែកខ្លាំងៗ ដើម្បីអោយមនុស្សម្នាឃើញ ។ មួយទៀត គាត់ចេះតែសុំឱ្យមានទីសំគាល់អស្ចារ្យ ដើម្បីបញ្ជាក់ថាមានព្រះជាម្ចាស់ តែការទាំងនេះ ព្រះយេស៊ូបានហាមនៅក្នុងម៉ាថាយ ១៦:៤ ។ អ្នកខ្លះខិតខំប្រកាសថា មានតែក្រុមជំនុំខ្លួនទេទើបជាក្រុមជំនុំពិតតែមួយ ។

«ខ្ញុំគ្រាន់តែចង់ដឹងសេចក្តីមួយប៉ុណ្ណោះ សូមបងប្អូនប្រាប់ខ្ញុំមើល៍ តើបងប្អូនបានទទួលព្រះវិញ្ញាណ មកពីបានប្រព្រឹត្តតាមវិន័យ ឬមកពីជឿដំណឹងល្អដែលបងប្អូនបានស្តាប់ ? ម្តេចក៏បងប្អូនល្ងីល្ងើម្ល៉េះ ! បងប្អូនបានចាប់ផ្តើមជីវិតថ្មី ដោយព្រះវិញ្ញាណ តែឥឡូវនេះ ម្តេចក៏ចង់បញ្ចប់ តាមរបៀបលោកីយ៍វិញដូច្នេះ ? » ។

(កាឡាទី ៣:២-៣)



«កុំបណ្តោយខ្លួនអោយឈ្លក់នឹងការស្រឡាញ់ប្រាក់ឡើយ គឺត្រូវស្កប់ចិត្តនឹងទ្រព្យសម្បត្តិ ដែលបងប្អូនមាននៅពេលនេះ ដ្បិតព្រះជា-ម្ចាស់មានព្រះបន្ទូលថា÷ "យើងនឹងមិនទុកអ្នកចោល ហើយក៏មិនបោះបង់អ្នកចោលដែរ" » ។

(ហេប្រឺ ១៣:៥)

នៅក្នុងប្រវត្តិសាស្ត្រក្រុមជំនុំទាំងមូល ចចកលោភលន់តែងតែធ្វើអោយការនាំព្រលឹងមកថ្វាយព្រះជាម្ចាស់ ក្លាយជាមុខជំនួញមួយ ។

ផ្លូវចិត្ត » ។ គ្រូគង្វាលដែលស្មោះត្រង់ អធិស្ឋានទូលសូមអោយអាចទប់ចិត្តខ្លួនឯង និង ប្រុងខ្លួនជានិច្ច ចៀសវាងមិនអោយធ្លាក់ក្នុងសេចក្តីល្បួងរបស់មារសាតាំង ។ ការដែលប្រសើរ គឺគ្រូគង្វាលត្រូវនាំភរិយារបស់ខ្លួន ឬ ស្ត្រីអ្នកជំនួយម្នាក់ទៅជាមួយ ពេលទៅសួរសុខទុក្ខស្ត្រី ។

ចចកលោភលន់

ចចកលោភលន់បំរើព្រះអង្គ ដើម្បីបានផលប្រយោជន៍ខាងសំភារៈ ។ គេមិនមែនធ្វើការងារ ដោយសារស្រឡាញ់ព្រះគ្រីស្តទេ ប៉ុន្តែ ដោយសារគេត្រូវបានអ្វីមួយ ។ គេដើរតាមព្រះអម្ចាស់ដើម្បីស្វែងរកនំប៉័ង និង ត្រី មិនមែនដើម្បីលើឈើឆ្កាងរបស់ខ្លួនទេ :

«មានមហាជនជាច្រើនធ្វើដំណើរជាមួយព្រះយេស៊ូ ។ ព្រះអង្គបែរព្រះភក្ត្រទៅរកគេ ហើយមានព្រះបន្ទូលថា៖ "បើអ្នកណាចង់មកតាមខ្ញុំ តែមិនស្រឡាញ់ខ្ញុំខ្លាំងជាងឪពុកម្តាយ ប្រពន្ធ កូន បងប្អូនប្រុសស្រី និង ជីវិតខ្លួនទេ អ្នកនោះពុំអាចធ្វើជាសាវ័ករបស់ខ្ញុំបានឡើយ ។ អ្នកណាមិនលីឈើឆ្កាងរបស់ខ្លួនមកតាមខ្ញុំទេ អ្នកនោះក៏ពុំអាចធ្វើជាសាវ័ករបស់ខ្ញុំបានដែរ" » ។

(លូកា ១៤:២៥-២៧)



ចចកដែលគោរពព្រះក្លែងក្លាយសម័យថ្មី

ចចកគោរពព្រះក្លែងក្លាយសម័យថ្មី បង្កើតព្រះថ្មីៗរបស់ពួកគេដោយសារម៉ាស៊ីនកុំព្យូទ័រ ។ ពួកគេបង្កើតគោលជំនឿ ដោយខ្លួនឯង ។



© Project WorldReach © SEAN

ឧទាហរណ៍ «ពួកស្មរបន្ទាល់ព្រះយេហូវ៉ា» ថា មានព្រះពិតពីរអង្គ ។ ពួកគេប្រកាសថា ព្រះគ្រីស្ត ជាព្រះមួយ ហើយព្រះយេហូវ៉ា ជាព្រះមួយផ្សេងទៀត ។ ពួកសត្វចចកទាំងនេះមិនមែន ជាស្មរបន្ទាល់ពិតរបស់ព្រះអម្ចាស់ទេ ពីព្រោះនៅក្នុងគម្ពីរ អេសាយ ៤៣:១០ ព្រះយេហូវ៉ាមានព្រះបន្ទូលថា ស្មរបន្ទាល់ពិតប្រាកដរបស់ព្រះអង្គ នឹងផ្សព្វផ្សាយដំណឹងល្អថា ព្រះជាម្ចាស់មានតែមួយ គឺមិនមែនពីរដូច «ពួកស្មរបន្ទាល់ព្រះយេហូវ៉ា» ប្រកាសនោះទេ ។

«ពួកជំនុំម័រម៉ូន» ក៏មានព្រះច្រើនដែរ ។ ពួកគេនិយាយថា សមាជិកម័រម៉ូនម្នាក់ៗនឹងត្រូវលើកតម្កើងឡើង រហូតទាល់តែពួកគេក្លាយទៅជាព្រះអាទិទេពរៀងៗខ្លួន ។ សមាជិកទាំងឡាយរបស់និកាយសម័យកាលថ្មី ចេះតែបញ្ជាក់ថា មនុស្សគ្រប់រូបជាព្រះ-អាទិទេព ហើយថាព្រះជាម្ចាស់ជាធម្មជាតិ ។

ចចកទស្សន៍ទាយ



ចចកទស្សន៍ទាយជឿលើអបិយ៍ជំនឿណាស់ ។ គេខំទាយអំពីអនាគត ដោយមើលផ្កាយ ប្រើមន្តអាគម និង ទាក់ទងជាមួយវិញ្ញាណ ដែលគេឧបមាថា ជាវិញ្ញាណរបស់មនុស្សស្លាប់ ។ ទុតិយកថា ១៨:១០-១៤ បានហាមប្រាមមិនឱ្យធ្វើបែបនេះទ ។

ចចកព្រានឥារី

គួរអោយសោកស្តាយណាស់ ដែលមានអ្នកជឹកនាំមួយចំនួនបណ្តោយខ្លួនអោយនិស្ស័យសាច់ឈាមជឹកនាំ នៅពេលទៅផ្តល់ជំបូន្មានដល់ស្ត្រី ។ ពួកអ្នកជឹកនាំទាំងនោះ ធ្វើអោយស្ត្រីទាំងនោះជាប់ចិត្តពឹងផ្អែកលើពួកគេ ។ ពួកគេឆ្លៀតកេងយកផល-ប្រយោជន៍ពីស្ត្រីទាំងនោះ ដោយមានទំនាក់ទំនងខុសច្បាប់ទម្លាប់ មិនបរិសុទ្ធជាមួយស្ត្រីទាំងនោះ ហើយសំអាងថា «ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់» ឬ «ដើម្បីព្យាបាលរបួស

© Project WorldReach © SEAN